ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ០២/០៦ - ហ្វារធ្យូន ហ្គាម៉ែន**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ :** ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសឡើងដោយភាគីនិយោជក : **លោក អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លោក ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **លោក ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១-ភាគីនិយោជក

ឈ្មោះ : **រោងចក្រកាត់ដេរ ហ្វារធ្យូន ហ្គាម៉ែន និងរ៉ូលលែនណែធីង ហ្វាក់តូរី**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២១ ភូមិព្រែកខ្សែវ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០២៤ ៣៩១ ២៨២ ០១៦ ៩៥៨ ៩៣៤ ទូរសារលេខ : ០២៣ ៣៦៥ ១៨២, ៤២៥ ០៣៥

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក សុខ ហាក់ | អនុប្រធានក្រុមហ៊ុន |
| ២- លោក លី លាង | ជំនួយការរដ្ឋបាល |
| ៣- លោក ឡុង ហ៊ាង | មន្ត្រីសម្របសម្រួលនៃសមាគមន៍កាត់ដេរ |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

អាសយដ្ឋាន : ផ្ទះលេខ ៦សេ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៨២ ៦៥៣ ទូរសារលេខ : គ្មាន

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793
E-mail: ac_sec@online.com.kh • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត :

១-លោក លន់ ស៊ីម៉េត ប្រធានសហជីព C.CAWDU ប្រចាំរោងចក្រ ហ្វរធ្យូន

២-លោក ធន វ៉ាន់ថា លេខាធិការសហជីព C.CAWDU ប្រចាំរោងចក្រ ហ្វរធ្យូន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីកម្មករនិយោជិតទាមទារកុំអោយក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ ដុល្លារ នៅពេលកម្មករធ្វើកូដកម្ម តែឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលថ្ងៃអាក់អានធ្វើការក្នុងពេលធ្វើកូដកម្ម ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០០៨ ក.ប.វ/គណ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៦ ។

## សវនាការ និង សេចក្តីសន្និដ្ឋាននីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សវនាការ និង សេចក្តីសន្និដ្ឋាននីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២ ០០៦ (១៤:០០ នាទី - ១៦:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

ក្រុមហ៊ុនកាត់ដេរ ហ្វរធ្យូន ហ្គាមែន និងវូលលែនណៃធីង ហ្វាក់តូរី មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ ២១ ភូមិព្រែកខ្សេវ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល មានជូលកម្មករនិយោជិតសរុបចំនួន [illegible] នាក់ ។

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលដំណឹងថាមានកូដកម្មមួយកើតឡើងនៅអគារតម្បាញ ដែលមានកម្មករផ្នែកតម្បាញសរុបចំនួន២១០នាក់ ស្នើសុំទាមទារកុំអោយក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥ដុល្លារ តែអោយក្រុមហ៊ុនកាត់ប្រាក់ឈ្នួលថ្ងៃអាក់ខានធ្វើការដោយសារធ្វើកូដកម្ម ។ បន្ទាប់មកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចុះធ្វើការផ្សះផ្សាដល់ទីតាំងរោងចក្រ ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នា លើការទាមទារចំនួន០១ចំណុចនោះទេ ។ ចំណុចមិនសះជានេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៦ ។ ក្រោយពីបានទទួលសំណុំរឿងនេះមក នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៦ វេលាម៉ោង ១៤:០០ រសៀល ភាគីទាំងអស់នៃវិវាទត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះហៅមកចូលរួមសវនាការ ។

នៅថ្ងៃសវនាការខាងលើនេះ ក្រោយពីក្រុមអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាបន្ថែមទៀត ប៉ុន្តែការផ្សះផ្សានេះ មិនបានឈានទៅដល់ការព្រមព្រៀងឡើយ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចធ្វើការពិចារណាលើបញ្ហានេះតាមនីតិវិធីនៃច្បាប់ការងារ ។

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក:**

១- លិខិតផ្ទេរសិទ្ធិជូនលោក ឡុង ហ៊ាង មន្ត្រីសម្របសម្រួលច្បាប់នៃសមាគមន៍កាត់ដេរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០០៦ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- លិខិតលេខ ០០៨ ក.ប.វ/កណ. ស្តីពីរបាយការណ៍ដោះស្រាយវិវាទការងាររួមនៅរោងចក្រកាត់ដេរ ហួរធ្យូន ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ ២០០៦ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ២០០៦ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល :**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ០០៩ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ០០៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦

THE ARBITRATION COUNCIL

**អង្គហេតុ**

ក្រុមហ៊ុនកាត់ដេរ ហ្វរធ្យូន ហ្គាមែន និងវូលលែនណៃធីង ហ្វាក់តូរី មានទីតាំងស្ថិតនៅផ្លូវជាតិលេខ២១ ភូមិព្រែកខ្សេវ ឃុំរការខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល មានជួលកម្មករនិយោជិតសរុបចំនួន ២០៣០នាក់ ។

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់ភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន កាត់ដេរ ហ្វរធ្យូន មានជួលកម្មករសរុបប្រមាណ ២០៣០នាក់ ដែលក្នុងនោះមានកម្មករផ្នែកតម្បាញប្រមាណ ២១០នាក់ ។ កម្មករផ្នែកតម្បាញប្រមាណ ២១០នាក់នេះ មានកម្មករប្រមាណ ២០នាក់ជាប្រធានក្រុម និងអ្នកកត់លេខឡូ គឺជាកម្មករធ្វើការយកប្រាក់ឈ្នួលគោល មិនធ្វើការដេរស៊ីឡូទេ។

-នៅថ្ងៃទី ២៨ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ក្រុមហ៊ុនបានធ្វើការកំណត់តំលៃឡូលេខ PN១៣៥ ដើម្បីកំណត់ដេរសាកល្បង អ្នកដេរលឿន មធ្យម និងយឺតបានប៉ុន្មាន ហើយបានដាក់ចេញនូវតំលៃ ៣,៩ ដុល្លារក្នុង១ឡូ។

-នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦ កម្មករស្នើសុំអោយតំលើងតំលៃឡូចំនួន ០,០៣ដុល្លារបន្ថែមពីលើ ៣,៩ដុល្លារក្នុង១ឡូ ដោយយល់ថា តំលៃឡូថោក ដេរបានតែមិនបានស្មើនឹងប្រាក់ឈ្នួលគោល ប៉ុន្តែកម្មករបន្តធ្វើការរហូតដល់ម៉ោង ១២:០០នាទី ហើយបន្ទាប់ពីពេលបាយថ្ងៃត្រង់រួច នៅម៉ោងចូលធ្វើការវិញ ទើបមានកូដកម្មកើតឡើង។

-នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦ ភាគីក្រុមហ៊ុនយល់ព្រមបន្ថែមជូន ៦០០រៀល ចំណែកឯកម្មករវិញស្នើសុំបន្ថែម ២០០រៀលទៀតក្នុងមួយឡូ ឱ្យបាន ៨០០រៀល ប៉ុន្តែ ភាគីក្រុមហ៊ុនមិនយល់ព្រមឡើយ។ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦នេះ ភាគីក្រុមហ៊ុនបានលើកឡើងថា ប្រសិនបើកម្មករទាំងអស់នាំគ្នាចូលធ្វើការវិញ ក្រុមហ៊ុនមិនកាត់ប្រាក់រង្វាន់ធ្វើការទៀតទាត់ ៥ដុល្លារឡើយ ។

-នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ មន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានចុះមកសម្រុះសម្រួល ភាគីនិយោជកអះអាងថា ឯកភាពបន្ថែមជូន ២០០រៀលទៀតក្នុងមួយឡូ ឱ្យបាន ៨០០រៀល ដូចការទាមទាររបស់កម្មករនិយោជិត តែសុំអោយកម្មករដាក់ពាក្យសុំមកក្រុមហ៊ុន ។

- កម្មករផ្នែកតម្បាញប្រមាណ ២១០នាក់ បានធ្វើកូដកម្មរយៈពេល២ថ្ងៃកន្លះ ចាប់ពីថ្ងៃទី០៣ ពេលរសៀល ដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ ដោយពុំមានតំណាងសហជីពមូលដ្ឋានដឹកនាំឡើយ គឺកម្មករម្នាក់ៗ ធ្វើការនៅផ្នែកតម្បាញនេះ ស្ម័គ្រចិត្តធ្វើកូដកម្មដោយខ្លួនឯង ដូច្នេះសហជីពមិនបានធ្វើការជូនដំណឹងឡើយ ។

-លោកប្រធានសហជីព C.CAWDU ប្រចាំក្រុមហ៊ុន បានអះអាងថា នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៥ ក្រុមហ៊ុនបានព្យួរការងារកម្មករប្រមាណជាង ១៥០០នាក់ ក្នុងនោះមានលោកជាប្រធានសហជីពម្នាក់ផងដែរ ។ ដោយសារថា នៅថ្ងៃទី០១ និងទី០២ ខែមករា ជាថ្ងៃអាទិត្យ និងចំថ្ងៃបុណ្យ ដូច្នេះ ក្រុមហ៊ុនបានអនុញ្ញាតអោយលោកចូលធ្វើការវិញនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦ ដែលជាថ្ងៃធ្វើកូដកម្ម ហេតុនេះលោកមិនបានដឹកនាំធ្វើកូដកម្មឡើយ ។

-នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ កម្មករនិយោជិតទាំងអស់ចូលធ្វើការជាធម្មតាវិញ ។

-ជាលទ្ធផលចុងក្រោយកម្មករនិយោជិត ទាមទារកុំឱ្យនិយោជកកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៥ ដុល្លារ ដោយសារពួកគេធ្វើកូដកម្មនោះ ។

## ហេតុផលនៃសេចក្តីសម្រេច

កម្មករនិយោជិត បានទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់រង្វាន់ធ្វើការទៀងទាត់សំរាប់ខែ ដែលពួកគេបានធ្វើកូដកម្ម។ ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវរកអោយឃើញថា តើកម្មករនិយោជិតត្រូវទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៥ដុល្លារឬទេ ក្នុងកំឡុងពេលធ្វើកូដកម្មតាមច្បាប់ស្តីពីការងារ ? តាមច្បាប់ស្តីពីការងារ មាត្រា៣២៤ ចែងថា " ***មុនធ្វើកូដកម្ម កម្មករនិយោជិត ត្រូវជូនដំណឹងមុនយ៉ាងតិច៧ថ្ងៃ គិតតែថ្ងៃធ្វើការជាក់ស្តែង*** " ។ នៅក្នុងបញ្ហានៃវិវាទនេះ ភាគីកម្មករមិនបានធ្វើការជូនដំណឹងជាមុនទេ គឺកម្មករផ្នែកតម្បាញទាំងអស់២១០នាក់ ស្ម័គ្រចិត្តដោយខ្លួនឯងបានធ្វើកូដកម្ម រយៈពេល២ថ្ងៃកន្លះ ចាប់ពីថ្ងៃទី០៣ ពេលរសៀល ដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ ដោយសារក្រុមហ៊ុនមិនឯកភាពតាមការស្នើសុំរបស់កម្មករ ដែលទាមទារប្រាក់បន្ថែមចំនួន ២០០រៀលទៀត ពីលើប្រាក់បន្ថែមដែលភាគីក្រុមហ៊ុនបានឯកភាពផ្តល់ជូនចំនួន ៦០០រៀល ក្នុង១ឡូនោះ ។

តាមច្បាប់ការងារ មាត្រា៣២០ កថាខ័ណ្ឌទី៤ សិទ្ធិធ្វើកូដកម្មអាចអនុវត្តបាន លុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជំលោះ ដោយមធ្យោបាយសន្តិវិធីជាមួយនិយោជក ។ នៅក្នុងវិវាទនេះកម្មករបានធ្វើកូដកម្មនៅក្នុងក្រុមហ៊ុនហ្វារធ្យូន គឺធ្វើឡើងដោយមិនបានជូនដំណឹងជាមុន និងមិនបានព្យាយាមប្រើប្រាស់ឱ្យអស់លទ្ធភាពក្នុងការដោះស្រាយវិវាទការងារទេ ។ ឧទាហរណ៍ៈ ក្នុងរយៈពេលធ្វើកូដកម្ម កម្មករនិយោជិតមិនបានចូលរួមធ្វើការដោះស្រាយវិវាទការងារនេះ ជាមួយក្រសួងការងារ ឬជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

THE ARBITRATION COUNCIL *

យោងតាមសេចក្តីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា កម្មករដែលធ្វើកូដកម្ម អាចទទួលបានប្រាក់រង្វាន់ធ្វើការទៀតទាត់ចំនួន៥ដុល្លារ ប្រសិនបើការធ្វើកូដកម្មនោះ ស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ។ ដូច្នេះ ប្រសិនបើកូដកម្មនោះបានធ្វើឡើងដោយស្របតាមនីតិវិធីច្បាប់ស្តីពីការងារ កម្មករទាំងអស់នោះ នឹងទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន៥ដុល្លារ សមាមាត្រទៅនឹងចំនួនថ្ងៃដែលកម្មករបានធ្វើការ ។ ផ្ទុយមកវិញ ប្រសិនបើកូដកម្មធ្វើឡើងដោយមិនស្របតាមនីតិវិធីច្បាប់ស្តីពីការងារ កម្មករទាំងអស់នោះមិនទទួលបាននូវប្រាក់រង្វាន់ធ្វើការទៀងទាត់ទេ ពីព្រោះពួកគេមិនបានមកធ្វើការទៀងទាត់ (សូមមើលសំណុំរឿងលេខ ០៤/០៣-Lida Gamant, ០៨/០៤-Wash Concept, ១៥/០៤-Lucky Zone, ១៦/០៤-Yada Printing, ២២/០៤-Raffles le Royal, ២៥/០៤-Standard Garment, ៤៧/០៤-Dai Young, ៥៦/០៤-Hui Ying, ១១១/០៤-Sun Shiny, ០៣/០៥-Flying Dragon និង ១២/០៥-P&E) ។ ក្នុងសំណុំរឿងនេះ កម្មករនិយោជិតនៅក្នុងផ្នែកតម្បាញ បានធ្វើកូដកម្មដោយខុសនីតិវិធីច្បាប់ ។ ដូច្នេះ សរុបមក ដោយសារកូដកម្មនេះ ធ្វើឡើងមិនបានអនុវត្តតាមនីតិវិធីនៃច្បាប់ការងារ នាំឱ្យការទាមទារប្រាក់រង្វាន់ធ្វើការទៀងទាត់ក្នុងកំឡុងពេលធ្វើកូដកម្ម មិនអាចទទួលយកបានឡើយ ។ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកត់សំគាល់ឃើញថា យោងតាមច្បាប់ការងារមាត្រា៣៣២ ចែងថា *កិច្ចសន្យាការងារត្រូវបានព្យួរនៅពេលធ្វើកូដកម្ម ។ ក្នុងកំឡុងពេលនៃកូដកម្ម គាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ ។ កម្មករនិយោជិតត្រូវទទួលបានការងាររបស់ខ្លួនវិញនៅពេលចប់កូដកម្ម* ។ អត្ថន័យនៃមាត្រានេះ គឺមានន័យថា កម្មករនិយោជិតដែលធ្វើកូដកម្មមិនអាចទទួលបាននូវប្រាក់ឈ្នួលទេ នៅកំឡុងពេលធ្វើកូដកម្ម ។ ទោះបីជាកូដកម្មនោះធ្វើឡើងដោយស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារក៏ដោយ ក៏កម្មករនិយោជិតទាំងអស់នោះ មិនអាចទទួលបានប្រាក់ឈ្នួលទេក្នុងពេលធ្វើកូដកម្ម (សូមមើលសំណុំរឿងលេខ ២២/០៤-Raffles le Royal) ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចចេញសេចក្តីបង្គាប់ដូចតទៅ :

## **<u>បង្គាប់</u>**

បដិសេធការទាមទាររបស់កម្មករនិយោជិតផ្នែកតម្បាញចំនួន២១០នាក់ ដែលទាមទារប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន៥ដុល្លារ សំរាប់ខែមករា ឆ្នាំ២០០៦ ក្នុងកំឡុងពេលធ្វើកូដកម្ម។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុក រី**

ហត្ថលេខា:------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឆួន ស៊ីដាន់**

ហត្ថលេខា:------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា:------------------------------